8

# សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារ

# កាត់បន្ថយនូវការចំណាយរបស់លោកអ្នក



NSW DPI, Virginia Brunton

**ដោយសារការមានចំការដែលចាត់ចែងកិច្ចការបានយ៉ាងល្អ លោកអ្នកអាចកាត់បន្ថយនូវការចំណាយរបស់លោកអ្នក និងបង្ការកុំឲ្យមានការផាកពិន័យនៅក្រោមច្បាប់បរិដ្ឋានរដ្ឋញូវសៅវែល។**



NSW DPI, Steven Honeywood

## លោកអ្នកអាចកាត់បន្ថយការចំណាយរបស់លោកអ្នកដោយៈ

ឆែកមើលប្រព័ន្ធបញ្ចេញបញ្ចូលទឹកនៅតាមចំការរបស់លោកអ្នក ដើម្បីឲ្យបានច្បាស់ប្រាកដថាទឹកប្រព័ន្ធបញ្ចេញបញ្ចូលទឹកមិនបានហូរហៀរចេញពីចំការរបស់លោកអ្នក ហើយមិនបង្ហូរចេញនូវជាតិជីគីមី សារធាតុគីមី និងដីដ៏មានតម្លៃ។

- ឲ្យមានការវិភាគដីដើម្បីឲ្យបានដឹងអំពីប្រភេទ និងចំនួនត្រឹមត្រូវនៃជាតិជីគីមីប្រើសំរាប់ដី និងដំណាំរបស់លោកអ្នក។
- និយាយទៅកាន់ក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែល តាមទូរស័ព្ទលេខ 02 4588 2107 ដើម្បីទទួលយកឱវាទស្តីអំពីរបៀបចៀសវាងការប្រើដាក់ជីគីមីច្រើនហួស។
- មិនត្រូវប្រើជីគីមីជិតពេកទៅនឹងព្រែក ស្ទឹង ឬទំនប់ទឹក។
- ឲ្យបានប្រាកដថាប្រព័ន្ធបង្ហូរទឹកនៅចំការរបស់លោកអ្នកអាចទប់យកទឹកភ្លៀង និងទឹកប្រព័ន្ធបញ្ចេញបញ្ចូលទឹកដែលហូរចេញពីកន្លែងដាំដំណាំទាំងអស់។
- ផ្ទុកទឹកនៅក្នុងប្រព័ន្ធបង្ហូរទឹក ទំនប់ទឹក ស្រះរក្សាទឹក ដីសើមដាំដំណាំ ឬផ្លូវស្មៅតម្រង។
- ដាក់ដីដែលត្រងយកដោយប្រព័ន្ធបង្ហូរទឹក និងទំនប់ទឹកចូលទៅក្នុងចំការរបស់លោកអ្នកវិញជាប្រក្រតី។
- បញ្ឈប់ដីកុំឲ្យហូរចេញទៅក្រៅ ដោយដាំរុក្ខជាតិគ្របពីលើ និងមិនទុកឲ្យវាលដាំដំណាំនៅល្ហល្ហេវចោលអស់រយៈពេលច្រើនអាទិត្យមុនពេលដាំដំណាំ។
- ជំរុញរុក្ខជាតិក្នុងស្រុកឲ្យដុះនៅក្បែរមាត់ព្រែក និងស្ទឹងទាំងឡាយ។ ការនេះនឹងជួយបង្ការកុំឲ្យមានការច្រោះដី និងជួយស្រូបយកជីវជាតិ និងជីគីមីដែលលើសពីសេចក្តីត្រូវការ។
- ដាំរុក្ខជាតិបាំងខ្យល់ នៅតាមបណ្តោយចំការរបស់លោកអ្នកដើម្បីបង្ការកុំឲ្យប៉ើងដី។

**សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារនេះ** គឺជាផ្នែកនៃលំដាប់ព័ត៌មានគ្រោងឡើងដើម្បីជួយដល់អ្នកដំណាំដែលមកពីសាវតាមិននិយាយភាសាអង់គ្លេស។ ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀត សូមទាក់ទងជាមួយសាលាក្រុងក្នុងតំបន់របស់លោកអ្នក។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទ TIS លេខ 131 450។

គំរោងការនេះបានទទួលការផ្គត់ផ្គង់ពីរដ្ឋាភិបាលរដ្ឋញូវសៅវែល តាមរយៈមូលនិធិបរិដ្ឋានរបស់ខ្លួន (Environmental Trust)។

ព័ត៌មានដែលចុះនៅក្នុងការចុះផ្សាយនេះសំអាងទៅលើចំណេះដឹង និងការដឹងយល់នៅចំពេលកំពុងសរសេរ (ខែវិច្ឆិកា ឆ្នាំ២០០៧)។ ទោះជាយ៉ាងណាក្តី ដោយព្រោះតែការចំរើនលើចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកប្រាប់ពីសេចក្តីត្រូវការដើម្បីឲ្យបានប្រាកដថាព័ត៌មានដែលគេពឹងផ្អែកនោះគឺទាន់ពេលថ្មីៗ ហើយត្រូវឆែកមើលព័ត៌មានបច្ចុប្បន្នជាមួយភ្នាក់ងារសមស្របនៃក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែល ឬជាមួយអ្នកប្រឹក្សាឯករាជ្យនៃអ្នកប្រើប្រាស់ព័ត៌មាននេះ។

NSW DEPARTMENT OF PRIMARY INDUSTRIES

NSW Environmental TRUST